**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧ សរណន

# សារាចរណែនាំ

## ស្តីពី

## ការចាត់ចែងរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ថ្វាយព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា គម្រប់ព្រះជន្ម ៨០ យាងចូល ៨១ ព្រះវស្សា

ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ គឺជាអាយុវឌ្ឍនមង្គលមួយដ៏ល្អប្រសើរថ្លៃថ្លារបស់ប្រជារាស្ត្រខ្មែរ ដែលប្រារព្ធឡើង ដើម្បីសំដែងនូវកតញ្ញុតាធម៌ចំពោះព្រះមហាករុណាធិគុណ ថ្វាយព្រះពរសព្ទសាធុការ និងថ្វាយមហាកុសលចំពោះ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាព្រះអគ្គមគ្គុទ្ទេសក៍ដំឡើម និងជាព្រះបិតាឯករាជជាតិ ផ្សះផ្សាបង្រួបបង្រួមជាតិ ទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះសុខមាលភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និងព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ របស់ប្រជារាស្ត្រខ្មែរយូរអង្វែងតរៀងទៅ ។

ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ខេត្ត-ក្រុង និងប្រជាពលរដ្ឋទូទាំងប្រទេស តែងបានប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ក្នុងរយៈពេល ៣ថ្ងៃ គឺថ្ងៃទី ៣០-៣១ ខែ តុលា និងថ្ងៃទី ០១ ខែ វិច្ឆិកា តាមប្រពៃណីជាតិ និងប្រពៃណីសាសនា ។

ឆ្នាំនេះ នាឱកាសដ៏នក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មរបស់ព្រះអង្គ គម្រប់ព្រះជន្ម ៨០ យាងចូល ៨១ ព្រះវស្សា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវសារាចរណែនាំដូចតទៅនេះ :

១- ប្រគល់ភារកិច្ចជូនក្រសួងព្រះបរមរាជវាំង និងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីសក្ការៈ ឱ្យបានសមស្រមទៅនឹងប្រពៃណីជាតិ និងប្រពៃណីសាសនា ។

២- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំតុបតែងលំអ ទង់ជាដោយភ្លើងពណ៌ តាំងព្រះឆាយាលក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** មានពាក្យស្លោកថ្វាយព្រះពរ និងសារថ្វាយព្រះពរ ព្រមទាំងបំផុសប្រជារាស្ត្រ អបអរសាទរដោយមានដោតទង់ជាតិគ្រប់គេហដ្ឋាន និងបដាពាក្យស្លោក ។

៣- គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម **ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តមសីហនុ** ក្នុងក្របខ័ណ្ឌខេត្ត-ក្រុងរបស់ខ្លួន ដោយមានមន្ត្រីសង្ឃ ថ្នាក់ខេត្ត-ក្រុង មន្ត្រីរាជការថ្នាក់ខេត្ត-ក្រុង មន្ទីរនានាជុំវិញខេត្ត-ក្រុង-ខ័ណ្ឌ-ស្រុក អ្នកមុខអ្នកការ ចូលរួមឱ្យបានឱឡារិក និងមានរៀបចំសារថ្វាយព្រះពរផង ។

៤- ក្រសួងពត៌មាន ត្រូវណែនាំចាត់តាំងឱ្យបណ្ដាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន តាមដានយកពត៌មាន ធ្វើការផលិតផ្សព្វផ្សាយព្រះរាជជីវប្រវត្តិ ស្នាព្រះហស្ត **ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តមសីហនុ** ឱ្យបានទូលំទូលាយ ។

៥- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈ និងចម្រៀង បុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តសប្បាយ នៅតាមទីសាធារណៈទាំងបីថ្ងៃ ដើម្បីចូលរួមអបអរសាទរក្នុងទិវាដ៏នក្ខត្តឫក្សនេះ ។

៦- ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យសហការការពារសន្តិសុខ របៀបរៀបរយ សណ្ដាប់ធ្នាប់សង្គម បំរើការរៀបចំព្រះរាជពិធីនេះ តាមសំណូមពរ ធានាសេចក្ដីសុខក្សេមក្សាន្ត និងភាពសប្បាយរីករាយជូនប្រជាពលរដ្ឋយើង ។

៧- ទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសម្ភារៈ និងថវិកាសម្រាប់បំរើការរៀបចំព្រះរាជពិធីបុណ្យនេះ ឱ្យបានសមស្រប និងទាន់ពេលវេលា ។

៨- គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវមានផែនការបែងចែកតាមក្រសួង រដ្ឋលេខាធិការដ្ឋាន មន្ទីរ ស្ថាប័ន អំពាវនាវសប្បុរសជន អង្គការក្រៅរដ្ឋាភិបាល អង្គការមនុស្សធម៌ ក្រុមហ៊ុនឯកជន ជួយឧបត្ថម្ភជា សម្ភារៈ ថវិកា គ្រឿងឧបភោគ បរិភោគផ្សេងៗ ចុះសួរសុខទុក្ខ ដល់យុទ្ធជនរបួស មានជម្ងឺ កំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ យុទ្ធជនពិការ នៅតាមមណ្ឌលពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យ គ្មានទីពឹង ដើម្បីសំដែងមនោសញ្ចេតនា អាណិតស្រឡាញ់ លើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ចាត់តាំងអនុវត្តស្មារតីសារាចរនេះ សំរេចបានលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងប្រពៃណីជាតិយើង ។/

រាជធានីភ្នំពេញ , ថ្ងៃទី១០ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោកសម្រាប់ប្រើប្រាស់
# ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទសម្តេច
# ព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងគម្រប់ព្រះជន្ម ៨០ យាងចូល ៨១ ព្រះវស្សា

១- សូមថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា មានព្រះរាជសុខុមាលភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

២- សូមថ្វាយព្រះពរសម្តេចឪ និងសម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៣- ជយោ ! សម្តេចឪ និងសម្តេចម៉ែ ។

៤- ជយោ ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា ។

៥- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ ។

៦- ជយោ ! ព្រះរាជាណាចក្រកម្ពុជា ។

៧- ជាតិ សាសនា ព្រះមហាក្សត្រ ។

៨- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍ ។

៩- ជយោ ! សម្តេចព្រះបិតាឯករាជជាតិ ។

១០- ជយោ ! សម្តេចព្រះបិតាសន្តិភាព ផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ ។